# បុរីចន្ទគីរី

បុរីចន្ទគីរី នឹងក្លាយជាគម្រោងអភិវឌ្ឍបុរីដំបូងបង្អស់របស់ក្រុមហ៊ុន Urbanland ។ បុរីនេះមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ ២ ដោយធ្វើដំណើរពីមហាវិថីសម្តេចតេជោហ៊ុនសែន ឬផ្លូវ៦០ម៉ែត្រដែលនៅភាគខាងត្បូងនៃរាជធានីភ្នំពេញ។

តាមរយៈការប្រកាន់ខ្ជាប់នូវវិធីសាស្ត្រផ្តោតលើតម្រូវការមនុស្សជាចម្បង ដើម្បីស្តាប់និងស្វែងយល់ពីអ្វីដែលអតិថិជនចង់បានពីគេហដ្ឋានរបស់ពួកគេ យើងបានរចនាផ្ទះថ្មីទាំងនេះដោយគិតគូរពីខាងក្នុងមកក្រៅពីព្រោះយើងប្តេជ្ញាបង្កើតផ្ទះដែលស័ក្តិសមនឹង តម្រូវការ និងក្តីប្រាថ្នារបស់មនុស្សគ្រប់រូប។

តាមរយៈការបំផុសគំនិតពីពាក្យ "ខ្លឹម" យើងបានផ្តួចផ្តើមនូវការបង្កើតលំនៅឋានដ៏មានផាសុកភាពដែលត្រូវ បានគិតគូរយ៉ាងល្អិតល្អន់ទៅលើគ្រប់ទីធ្លាក្នុងផ្ទះ អមជាមួយការរចនាដ៏ប្រណីត ផ្តល់នូវចរន្តខ្យល់ចេញចូល និងពន្លឺថ្ងៃធម្មជាតិដែលជួយឲ្យការរស់នៅកាន់តែប្រសើរ។ បុរីចន្ទគីរីនឹងមានរួមបញ្ចូលនូវប្រភេទផ្ទះជាច្រើន ដែលក្នុងនោះរួមមាន វីឡាកូនកាត់ វីឡាភ្លោះ និងវីឡាទោលជាដើម។ ក្នុងនោះផងដែរ យើងក៏មានសេចក្តីរំភើបយ៉ាងខ្លាំងក្នុងការណែនាំប្រភេទផ្ទះថ្មីមួយ គឺប្រភេទវីឡាភ្លោះតូច។

ការរស់នៅហ៊ុមព័ទ្ធដោយធម្មជាតិ និងសហគមន៍ល្អមួយជាកត្តាពង្រឹងឲ្យជីវិតរស់នៅកាន់តែមានភាពពេញលេញ និងប្រកបដោយផាសុកភាព។ ការរស់នៅក្នុងបុរីចន្ទគីរី នឹងផ្តល់ឱកាសឲ្យលោកអ្នកផ្ចិតយកធម្មជាតិដ៏ស្រស់បំព្រងនៅក្នុងផ្ទះ និងបរិវេណសួនច្បារ ដែលត្រូវបានរចនាដោយគិតគូរអំពីសុវត្ថិភាព និងសន្តិសុខជាចម្បង។ សួនច្បារទាំងនេះអាចជួយជំរុញដល់ការប្រាស្រ័យទាក់ទងគ្នាជាមួយអ្នកជិតខាង មិត្តភ័ក្តិ ព្រមទាំងមនុស្សជាទីស្រឡាញ់ ដើម្បីចំណាយពេលវេលាដ៏មានតម្លៃជាមួយគ្នា និងបង្កើតនូវសហគមន៍មួយដែលប្រកបទៅដោយភាពស្រស់បំព្រង និងភាពរស់រវើក។

តាមរយៈការប្តេជ្ញាចិត្តរបស់យើងទៅលើ គុណភាព ភាពបិតថេរ និងភាពផ្ចិតផ្ចង់ យើងខ្ញុំសូមស្វាគមន៍លោកអ្នកក្នុងការបោះជំហានទៅរកការរស់នៅកាន់តែប្រសើរមួយនៅប្រទេសកម្ពុជា ជាមួយបុរីចន្ទគីរី។











សម្រាប់ការចាប់អារម្មណ៍ សូមទាក់ទងលេខ ៖ 061 888 580/ 078 888 580 ឬ

អ៊ីមែល info@urbanlandasia.com.